# ដំណើរកាត់វិសាលភាព

១៨ កក្កដា - ៦ កញ្ញា ២០១៤

## ភីត ពិន
## អេមី លី ស៊ែនហ្វត
## សឿន សំ

រៀបចំពិព័រណ៍ដោយ វុធ លីណូ





102 Jan. 28, 1974: 11.30 a.m.

My sweet Hony-

This morning about 6 a.m. a rocket fell about 400 meters behind our apartment. I jumped out of bed and ran over to Amy's room. At the same time the cook and Amy's nurse arrived. The cook fetched Amy and we all crowded in the corridor near the bed-room. The sound was horrible. It fell fortunately on the street where nobody was walking. The nurse was frightened. But strange enough I was ... The pieces of the rocket ... houses near



From top: **Seoun Som**, *Devoid of Presence 2*, 2009, dye-sublimation on polyester chiffon, 152x152cm. **Amy Lee Sanford**, *Jan 28, 1974*, 2013, archival pigment print, 60x30cm. **Pete Pin**, *Untitled*, from series *Cambodian Diaspora: Memory*, 2014, archival pigment print, 91x152cm.

ពិព័រណ៍សិល្បៈ កម្មវិធីសាធារណៈ និង សៀវភៅកាតាឡុកនៃគម្រោង *ដំណើរកាត់វិសាលភាព*
អាចប្រព្រឹត្តទៅបានក្រោមការគាំទ្រពីស្ថានទូតសហរដ្ឋអាមេរិកប្រចាំនៅក្នុងភ្នំពេញ ប្រទេសកម្ពុជា។

*ដំណើរកាត់វិសាលភាព* ពិនិត្យនិងអញ្ជើញឲ្យមានការពិភាក្សាអំពីសហគមន៍ប្រជាជនខ្មែររស់នៅ សហរដ្ឋអាមេរិក តាមរយៈស្នាដៃរបស់សិល្បករខ្មែរ-អាមេរិកាំងចំនួនបីរូប គឺ ភីត ពិន  អេមី លី ស៊ែនហ្វត និង សឿន សំ។ សិល្បករនីមួយៗ ប្រើប្រាស់លទ្ធភាពផ្សេងៗនៃការថតរូបនិងសម្ភារៈរូបថតជាការអនុវត្តសិល្បៈ។

ការធ្វើចំណាកស្រុករបស់ប្រជាជនខ្មែរក្នុងទ្រង់ទ្រាយធំជាលក្ខណៈអន្តរជាតិ នៅក្នុងប្រវត្តិសាស្ត្រចុង ក្រោយនេះ គឺភាគច្រើនត្រូវបានគេចាត់ទុកថាមានការជាប់ទាក់ទងនឹងសង្គ្រាមស៊ីវិលក្នុងស្រុក ដែលចាប់ផ្ដើម ក្នុងទសវត្សឆ្នាំ១៩៦០ នឹងដែលបានបញ្ចប់ដោយរបបប្រល័យពូជសាសន៍ក្នុងចន្លោះពីឆ្នាំ១៩៧៥-៧៩។ ក្នុង ចំណោមប្រជាជនដែលបាននិរទេសខ្លួន មានមួយចំនួនធំបានទៅរស់នៅក្នុងសហរដ្ឋអាមេរិក ក្នុងអំឡុងទសវត្ស ឆ្នាំ១៩៧០ និង១៩៨០។ *ដំណើរកាត់វិសាលភាព* មិនមានបំណងបង្កើតនូវរូបភាពតំណាងជាឯកភាពមួយនៃ សហគមន៍ខ្មែរអាមេរិកាំងក្នុងទឹកដីសហរដ្ឋអាមេរិកនោះទេ ប៉ុន្តែទទួលស្គាល់នូវបទពិសោធន៍ចម្រុះផ្សេងៗគ្នារបស់ ពួកគាត់ និងផ្ដល់នូវមធ្យោបាយមួយចំនួនដើម្បីបើកនិងបង្កើតឲ្យមានការស្វែងយល់អំពីភាពស្មុគ្រស្មាញទាំងនេះ។

*ដំណើរកាត់វិសាលភាព* ពិនិត្យមើលទៅលើប្រភេទនៃឱកាសផ្សេងៗ ដែលសិល្បករនីមួយៗចង់ បង្កើតនិងនាំផ្លូវទៅរកការភ្ជាប់(ឡើងវិញ)ជាមួយប្រវត្តិរបស់គាត់ និងស្រម័យ(ឡើងវិញ) អំពីពិភពនៃអត្តន័យ របស់គាត់។ អេមី លី ស៊ែនហ្វត ស្វែងរកប្រវត្តិឫសគល់និងទីពំនាក់របស់នាង តាមរយៈការផ្ដុំសំបុត្រទាំងឡាយ ដែលឪពុករបស់នាងបានផ្ញើមកឲ្យនាង មុនពេលគាត់បាត់ខ្លួនក្នុងឆ្នាំ១៩៧៥ បន្ទាប់ពីខ្មែរក្រហមបានឡើងកាន់ អំណាចភ្លាម។ ក្នុងស្នាដៃ *Fragments* (២០១៣) អេមី  បានបោះពុម្ពឡើងវិញនូវបំណែកដកស្រង់មួយចំនួន ពីលិខិតឆ្លើយឆ្លងសរសេរដោយដៃដែលឪពុកនាងបានផ្ញើមក។ បំណែកទាំងនេះត្រូវបានរៀបចំតម្លើងផ្គុំគ្នាជា លក្ខណៈកំណាព្យ ដែលនឹងត្រូវផ្លាស់ប្ដូរជាច្រើនដងក្នុងអំឡុងពេលតាំងពិព័រណ៍នេះ។ ដំណើរការផ្ដុំបំណែកនៃ ការចងចាំនេះ ត្រូវបានបញ្ជាក់កាន់តែច្បាស់ថែមទៀតនៅក្នុងស្នាដៃ *Cascade (36)* (២០១៤) ដែលជាវីដេអូ ១ ប៉ុស្តិ៍ បង្ហាញពីដៃរបស់សិល្បករ កំពុងរៀបចំផ្គុំព័ត៌មានដែលរាយប៉ាយ។ តាមរយៈដំណើរការបង្កើតឱកាស ផ្ទាល់ខ្លួនបែបសមាធិ ប្រកបដោយភាពច្នៃប្រឌិតនេះ  អេមី ប្រឈមនឹងបញ្ហាធំៗជាងនេះដែលទាក់ទងនឹងភាព ជាប់គាំងខាងផ្លូវអារម្មណ៍និងការផ្សះផ្សារផ្លូវចិត្ត ព្រមទាំងស្វែងរកជីវប្រវត្តិដែលមិនទាន់ពេញលេញនិងមាន លំនឹងរបស់ខ្លួននាង របស់ឪពុកនាង និងរបស់ប្រទេសកម្ពុជាផងដែរ។

ខណៈដែលស្នាដៃរបស់ អេមី ពឹងផ្អែកទៅលើការសញ្ជឹងគិតជាលក្ខណៈបុគ្គល សិល្បករ ភីត ពិន ប្រើប្រាស់ការថតរូបជាដំណើរការសម្រាប់ការចូលរួមរបស់ពលរដ្ឋ និងជាកាតាលីករសម្រាប់ការពិភាក្សាក្នុង ចំណោមគ្រួសារខ្មែរ-អាមេរិកាំង នៅសហរដ្ឋអាមេរិក។ ស្នាដៃ *Cambodian Diaspora: Memory* (២០១០- កំពុងបន្ត) គឺជាកម្រងរូបថតពីរជាប់គ្នា ដែលមានរូបជនចំណាកស្រុកភៀសខ្លួនខ្មែរម្នាក់ដែលថតក្នុងស្ទូឌីយ៉ូ និងរូបឯកសារបណ្ណសារមួយ។ ឯកសារចាស់ៗទាំងនេះ ដោយរួមមានរូបថតដែលបានថតនៅជំរុំជនភៀសខ្លួន សំបុត្រយន្តហោះ និងឯកសារសំខាន់ផ្សេងៗទៀត គឺជាកំណត់ត្រាប្រវត្តិសាស្ត្រដែលត្រូវបានសមាជិករបស់ គ្រួសារក្នុងរូបថតជ្រើសរើសសម្រាប់សិល្បករ។ តាមរយៈការបង្កើតដំណើរការពិនិត្យឡើងវិញនិងជ្រើសរើស ឯកសារបណ្ណសារទាំងនេះ ភីត បានបង្កើតឱកាសមួយសម្រាប់ឪពុកម្ដាយនិងកូនៗឲ្យចូលរួមពិភាក្សាគ្នា អំពី ប្រវត្តិសាស្ត្រដ៏លំបាក និងបន្តផ្ទេរការចងចាំទាំងនោះ។ ភាពផ្ទុយគ្នារវាងផ្ទៃខាងក្រោយពណ៌ខ្មៅរបស់រូបដែល ទើបថតថ្មី និងផ្ទៃខាងក្រោយពណ៌សនៃរូបឯកសារបណ្ណសារ ជំរុញឲ្យមានអារម្មណ៍តានតឹងមួយរវាងបច្ចុប្បន្ន កាលដែលហាក់កំពុងរសាត់បាត់ទៅ ជាមួយនឹងការចងចាំដែលកំពុងលេចឡើងវិញ។

ក្នុងស្នាដៃ *Devoid of Presence* (២០០៩) សឿន សំ បង្ហាញរូបថតពណ៌ស-ខ្មៅបោះពុម្ពនៅលើ កំណាត់ថ្លាស្តើង ដើម្បីបង្ហាញអំពីសភាពមិនអចិន្ត្រៃយ៍នៅរវាងពិភពផ្សេងៗគ្នារបស់គាត់។ តាមរយៈការដាក់ បញ្ចូលគ្នានូវរូបភាពនៃការប្រតិបត្តិសាសនានិងប្រពៃណី រវាងពីប្រទេសកម្ពុជានិងសហរដ្ឋអាមេរិក សឿន បាន ចោទជាសំណួរនិងជំនះទៅលើទស្សនៈអំពីអត្តសញ្ញាណស្ថិតស្ថេររបស់ពលរដ្ឋម្នាក់ដែលធ្វើដំណើរកាត់ប្រទេស ផ្សេងៗគ្នាជាច្រើន។ នៅក្នុងការតម្លើងថ្មីសម្រាប់ពិព័រណ៍នេះ អ្នកទស្សនាត្រូវបានអញ្ជើញឲ្យដើរកាត់តាមចន្លោះ រូបភាពធំៗចំនួនបួនផ្ទាំង ដែលព្យួរស្របគ្នាក្នុងលំហនៅចំកណ្ដាលវិចិត្រសាល។ នៅពេលដែលយើងដើរកាត់ក្នុង ពិព័រណ៍នេះ អ្វីដែលយើងឃើញនឹងប្រែប្រួលជានិច្ច ធ្វើឲ្យយើងមិនអាចកំណត់អំពីភាពនឹងស្ថិតស្ថេរបានឡើយ។

**ភីត ពិន** កើតក្នុងឆ្នាំ១៩៨២ នៅជំរុំខាវអ៊ីដាង នៃព្រំដែនកម្ពុជា-ថៃ ហើយបានធ្វើចំណាកស្រុកទៅ កាន់រដ្ឋកាលីហ្វ័រនីយ៉ាក្នុងពាក់កណ្ដាលទសវត្សឆ្នាំ១៩៨០។ គាត់ទទួលបានបរិញ្ញាប័ត្រមកពីសាកលវិទ្យាល័យ California នៅ Berkeley និងបានរៀនផ្នែករូបថតឯកសារនិងអ្នកកាសែតថតរូប នៅមជ្ឈមណ្ឌល ICP ក្នុង ទីក្រុងញូយ៉ក ដែលជាកន្លែងដែលគាត់បានទទួលអាហារូបករណ៍ Allan L. Modotti។ ភីត រស់នៅនិងធ្វើការ នៅប្រ៊ូកគ្លីន ក្រុងញូយ៉ក។ គាត់គឺជាអ្នកទទួលអាហារូបករណ៍ពី Magnum Foundation Emergency Fund និងត្រូវបាន Getty Image ចុះឈ្មោះថាជាអ្នកមានទេពកោសល្យថ្មីក្នុងយុគរាយការណ៍ព័ត៌មាន។ គាត់ក៏ធ្វើការ ជាអ្នកកែសម្រួលរូបថតឲ្យ *TIME*  ដែរ។ ពេលបច្ចុប្បន្ននេះ គាត់ធ្វើការក្នុងគម្រោងរយៈពេលវែងមួយជាមួយ សហគមន៍ខ្មែរជាច្រើននៅសហរដ្ឋអាមេរិក ដោយប្រើប្រាស់ការថតរូប ដើម្បីបង្កើតការពិភាក្សាជុំវិញបញ្ហាអំពី ប្រវត្តិសាស្ត្រគ្រួសារនិងសហគមន៍។ ការងាររបស់គាត់ត្រូវបានបោះពុម្ពផ្សាយនៅក្នុង *New York Times*, *TIME Magazine*, *Forbes* និង *Burn* ។ គាត់ក៏ជាអ្នករៀបចំពិព័រណ៍ *FORWARD: Modern Arts Festival* (២០១៣), ដែលបានតាំងបង្ហាញស្នាដៃរបស់សិល្បករចំណាកស្រុកខ្មែរ នៅ Gowanus Loft, ប្រ៊ូកគ្លីន, ក្រុងញូយ៉ក។ ពិព័រណ៍ជាក្រុមថ្មីៗរបស់គាត់រួមមាន *Our Portraits, Our Families* នៅសារមន្ទីរជនជាតិចិនក្នុងសហរដ្ឋអាមេរិក (២០១៤)។ ភីត ធ្លាប់ជាសិល្បករនិវាសដ្ឋាននៅសារមន្ទីរ Bronx ដែលជាផ្នែកមួយនៃមហោស្រពសិល្បៈចម្រុះ *Season of Cambodia* នៅក្រុងញូយ៉ក ឆ្នាំ២០១៣។ ព័ត៌មានបន្ថែមអំពី ភីត ពិន www.petepin.com ។

**អេមី លី ស៊ែនហ្វត** កើតក្នុងឆ្នាំ១៩៧២ ក្នុងប្រទេសកម្ពុជាក្នុងអំឡុងពេលអស្ថេរភាពនយោបាយនិង មានសង្គ្រាមស៊ីវិល មុនពេលដែលឪពុករបស់នាងបានបញ្ជូននាងទៅរស់នៅសហរដ្ឋអាមេរិក ពេលដែលនាងមាន អាយុ២ឆ្នាំ។ អេមី បញ្ចប់ការសិក្សាបរិញ្ញាប័ត្រផ្នែកសិល្បៈចក្ខុទស្សន៍ ពីសាកលវិទ្យាល័យ Brown។ នាងបានរស់ នៅនិងធ្វើការក្នុងក្រុងភ្នំពេញតាំងពីឆ្នាំ២០០៦។ សំណុំសំបុត្រជាច្រើនពីឪពុករបស់នាង គឺជាប្រភពដ៏សំខាន់ មួយនៃការជំរុញទឹកចិត្ត សម្រាប់ការអនុវត្តបង្កើតសិល្បៈរបស់នាង។ នាងធ្វើការជាមួយសម្ភារៈចម្រុះរួមមានទាំង Performance ផងដែរ។ ការងាររបស់ អេមី ស្វែងរកការវិវត្តនៃការជាប់គាំងខាងផ្លូវអារម្មណ៍ និងផលប៉ះពាល់យូរ អង្វែងនៃសង្គ្រាម ដោយរួមមានទាំងទិដ្ឋភាពទាក់ទងនឹងការធ្វើខុស ការបាត់បង់ ភាពខុសពីគេ និងការផ្លាស់ទី លំនៅ។ ពិព័រណ៍និង Performance ទោលថ្មីៗរបស់គាត់រួមមាន *Break Pot Performance:Gertrude Street* នៅវិចិត្រសាលទី៧ ក្រុងមែលប៊ិន(២០១៣), *40 Pots + 4 Sketches* (២០១៣) និង *Full Circle* (២០១២) នៅ Java Arts ក្រុងភ្នំពេញ។ ពិព័រណ៍ជាក្រុមថ្មីៗរួមមាន *១៩៧៥* នៅ Topaz Arts ក្រុងញូយ៉ក, *new artefacts* នៅ ស-ស បាសាក់ ក្រុងភ្នំពេញ (២០១២) និង *London Biennale* (២០០៨)។ អេមី ធ្លាប់ជាសិល្បករ និវាសដ្ឋាននៅ ក្រុមប្រឹក្សាវប្បធម៌ Lower Manhattan ដែលជាផ្នែកមួយនៃ មហោស្រពសិល្បៈចម្រុះ *Season of Cambodia* នៅក្រុងញូយ៉ក ឆ្នាំ២០១៣។ ព័ត៌មានបន្ថែមអំពី អេមី លី ស៊ែនហ្វត www.amyleesanford.com ។

**សឿន សំ** កើតក្នុងឆ្នាំ១៩៧៩ នៅជំរុំជនភៀសខ្លួនសាកែវ២ នៃព្រំដែនកម្ពុជា-ថៃ និងបានទៅរស់នៅ ប្រទេសអូស្ត្រាលីក្នុងឆ្នាំ១៩៨៦។ គាត់ធំដឹងក្ដីនៅក្នុងរដ្ឋអាដឺលែដ ប្រទេសអូស្ត្រាលី តែក្រោយមកបានផ្លាស់ទៅ រស់នៅសហរដ្ឋអាមេរិក។ គាត់បញ្ចប់ការសិក្សាបរិញ្ញាប័ត្រពីសាកលវិទ្យាល័យ Youngstown State ក្នុងរដ្ឋ Ohio និងអនុបណ្ឌិតផ្នែកសិល្បៈពីសាកលវិទ្យាល័យ North Carolina នៅ Chapel Hill។ ដោយប្រើប្រាស់សម្ភារៈចម្រុះ ការងារសិល្បៈរបស់ សឿន សម្ដែងចេញអំពីបញ្ហាបុគ្គលនិងបញ្ហាសាកល ដោយបង្កើតបានជាចំណងរូបារម្មណ៍ រវាងបទពិសោធន៍ជីវិតផ្ទាល់របស់គាត់ក្នុងនាមជាជនជាតិខ្មែររស់នៅបរទេស និងទឹកដីដូនតាដ៏អាឡោះអាល័យ ដែលគាត់មិនដែលមានបទពិសោធន៍រស់នៅ។ រូបថត ចម្លាក់ និងការតម្លើងរបស់គាត់ លើកឡើងអំពីភាពមិនចុះ សម្រុងរវាងពិភព ២ ប៉ុន្តែឆ្លុះបញ្ចាំងអំពីលទ្ធភាពគ្មានព្រំដែនដែលកើតចេញពីភាពលាយឡំនៃវប្បធម៌ផ្សេងគ្នា។ ពិព័រណ៍ទោលថ្មីៗរបស់ សឿន រួមមាន *Devoid of Presence* នៅសាលកវិទ្យាល័យ Ohio, Athens (២០១៣)។ ពិព័រណ៍ជាក្រុមរួមមាន *FORWARD: Modern Arts Festival* (២០១៣), នៅ Gowanus Loft, ប្រ៊ូកគ្លីន, ក្រុង ញូយ៉ក; *Come Out and Play Art Festival*, នៅ Pittsboro, NC (២០១២) និង *Plugged In* នៅវិចិត្រសាល Lump, Raleigh, NC (២០១១) ។ សឿន ធ្លាប់បង្រៀនថតរូបនៅសាកលវិទ្យាល័យ North Carolina នៅ Chapel Hill ពីឆ្នាំ២០១០ ដល់ ២០១២។ ព័ត៌មានបន្ថែមអំពី សឿន សំ www.seounsom.com ។

ស-សបាសាក់ SA SA BASSAC
#18 2nd Floor, Sothearos Boulevard
PO Box 2181 Phnom Penh 3, Cambodia
+855 (0)77 774 864
www.sasabassac.com

# Traversing Expanses

18 July - 6 September 2014

## Pete Pin
## Amy Lee Sanford
## Seoun Som

curated by Vuth Lyno





102 Jan. 28, 1974: 11.30 a.m.

My sweet Honey -

This morning about 6 a.m. a rocket fell about
400 meters behind our apartment. I jumped out
of bed and ran over to Amy's room. At the same
time the cook and Amy's nurse arrived. The
cook fetched Amy and we all crowded in the
corridor near the bed-room. The sound was
horrible. It fell fortunately on the street
where nobody was walking. The nurse was
frightened. But strange enough, I was
The pieces of the rocket



From top: **Seoun Som**, *Devoid of Presence 2*, 2009, dye-sublimation on polyester chiffon, 152x152cm. **Amy Lee Sanford**, *Jan 28, 1974*, 2013, archival pigment print, 60x30cm. **Pete Pin**, *Untitled*, from series *Cambodian Diaspora: Memory*, 2014, archival pigment print, 91x152cm.

*Traversing Expanses* exhibition, public program, and catalog is made possible with support from The Embassy of the United States of America, Phnom Penh, Cambodia.

សា-សា បាសាក់ SA SA BASSAC
#18 2nd Floor, Sothearos Boulevard
PO Box 2181 Phnom Penh 3, Cambodia
+855 (0)77 774 864
www.sasabassac.com

*Traversing Expanses* explores and invites dialogue about Cambodian diaspora communities in the United States through works by three Cambodian-American artists: Pete Pin, Amy Lee Sanford and Seoun Som. Each artist challenges the possibilities of the photographic medium and its materiality as an art practice.

Mass international migration of Cambodians in modern history is most commonly cited in connection to internal civil wars commencing in the late 1960s, culminating in the genocidal regime of the 1975-79. Among the exiled population, a large number resettled in the United States during the 1970s and 1980s. *Traversing Expanses* does not attempt to build a unified representation of Cambodian-American communities in the US, but instead acknowledges the diversity of diasporic experiences and offers some ways to open up and build some understanding of this complexity.

*Traversing Expanses* looks at different kind of spaces that each artist attempts to create and navigate in (re)connecting to their own histories and (re)imagining their worlds of meaning. Amy Lee Sanford internally searches for her roots and sense of belonging through piecing together letters sent from her father before he disappeared in 1975, shortly after the Khmer Rouge took power. In *Fragments* (2013), Sanford presents prints of enlarged scanned sections from her father's hand-written correspondence. The prints are arranged in a poetic configuration that will shift several times over the course of the exhibition. This process of piecing together fragments of memories is intensified in *Cascade (36)* (2014), a single channel video that shows the artist's hands joining blocks of scattered information. Through this process of creatively engineering a personal, meditative space, Sanford confronts larger issues of emotional stagnation and reconciliation, as well as mapping the still unsettled portrait of herself, her father and Cambodia.

Whereas Sanford's work is based in personal contemplation, Pete Pin uses photography as a process for civic engagement, and a catalyst for inter-generational dialogue among Cambodian-American families across the United States. *Cambodian Diaspora: Memory* (2010-ongoing) is a series of diptychs comprising of a newly photographed studio portrait of a Cambodian refugee migrant and an archival document. These old documents including photographs taken at refugee camps, plane tickets and other ephemera that constitute a tangible historical record, are collectively chosen for Pin's photographs by the members of each depicted family. Through initiating the process of reviewing and selecting the archival materials, Pin creates a discursive space for parents and children to engage in discussions about difficult histories, and to pass on memories. The contrast between the black background of each newly produced portrait, and the white background for the image of the archival document, invokes a feeling of tension between a seemingly fading present and resurfacing memory.

In *Devoid of Presence* (2009), Seoun Som presents manipulated black and white photographs printed on sheer fabric to convey his state of transience between worlds. Through a juxtaposition of images of religious practices and other traditions from Cambodia and the United States, Som questions and challenges the notion of a fixed identity for a worlds-traversing citizen. In the exhibited iteration of this installation, audiences are invited to walk between four large works, suspended in space paralleled to each other in the middle of the gallery. As we move through the exhibition, what we see continuously varies, making it impossible to perceive or define a fixed state.

**About the Artist**

**Pete Pin** was born in 1982 in Khao-I-Dang refugee camp on the Thai-Cambodian border, and migrated to California in the mid-1980s. He holds a BA from the University of California at Berkeley and studied documentary and photojournalism at the International Center of Photography in NYC, where he was awarded the Allan L. Modotti Scholarship. Pin lives and works in Brooklyn, NYC. He was the 2011 Fellow at the Magnum Foundation Emergency Fund and was named an Emerging Talent in Reportage by Getty Images. He also works part-time for *TIME* as a Photo Editor. Pin is currently working on a long-term project with different Cambodian diasporic communities across the US, using documentary photography to generate dialogue around their familial and collective histories. Pin's work has been published in the *New York Times*, *TIME Magazine*, *Forbes*, and *Burn*, among others. He was curator of *FORWARD: Modern Arts Festival* (2013), a group exhibition of Cambodian diasporic artists at Gowanus Loft, Brooklyn, NY. Pin's most recent group exhibitions include *Our Portraits, Our Families,* at Museum of Chinese in America (2014). Pin was an artist-in-residence at the Bronx Museum, as part of *Season of Cambodia*, an interdisciplinary citywide art festival in NYC, 2013. More about Pete Pin at www.petepin.com.

**Amy Lee Sanford** was born in 1972 in Cambodia during a period of political instability and civil war, before her father arranged to send her to live in the US when she was two years old. Sanford holds a BA in Visual Arts from Brown University. She has lived and worked in Phnom Penh since 2006. A large collection of her father's letters has been one of the main sources of inspiration and departure for her art making practice. She works in both two and three dimensions across various media, including performance. Sanford's work explores the evolution of emotional stagnation, and the lasting effects of war, including aspects of guilt, loss, alienation, and displacement. Recent solo exhibitions and performances include *Break Pot Performance: Gertrude Street*, at Seventh Gallery, Melbourne (2013); *40 Pots + 4 Sketches* (2013) and *Full Circle* (2012) both at Java Arts, Phnom Penh. Recent group exhibitions include *1975* at Topaz Arts, NYC (2013); *new artefacts* at SA SA BASSAC, Phnom Penh (2012); and *London Biennale* (2008). Sanford was an artist-in-residence at Lower Manhattan Cultural Council as part of *Season of Cambodia*, an interdisciplinary citywide art festival in NYC, 2013. More about Amy Lee Sanford at www.amyleesanford.com.

**Seoun Som** was born in 1979 in Sa Kaeo II refugee camp on the Thai-Cambodian border, and resettled in Australia in 1986. Raised in Adelaide, Australia, Som later moved to live in the US. He holds a BA from Youngstown State University in Ohio and a MFA from the University of North Carolina at Chapel Hill. Employing various media, Som's art practice speaks to both the personal and the universal, forming metaphorical connections between his lived experiences as a Cambodian abroad and a nostalgic ancestral land that he never experienced. His photos, sculptures, and installations address the conflict inherent in being stuck between two worlds, yet also reflect the limitless possibilities inherent in hybridity. Som's most recent solo exhibition was *Devoid of Presence*, Ohio University, Athens, OH (2013). Group exhibitions include *FORWARD: Modern Arts Festival* at Gowanus Loft, Brooklyn, NY (2013); *Come Out and Play Art Festival*, Pittsboro, NC (2012) and *Plugged In* at Lump Gallery, Raleigh, NC (2011). Som also taught photography at The University of North Carolina at Chapel Hill from 2010-2012. More about Seoun Som at www.seounsom.com.